៦.៨- សារាចរលេខ ០១៣ សហវ. ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់មុខទំនិញ និង សេវាកម្មចាំបាច់មួយចំនួនដែលត្រូវប្រើប្រាស់បន្ទាន់នៅដើមឆ្នាំថវិកា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ..០១៩៨.......សហវ.......

# សារាចរណែនាំ
# ស្តីពី
# ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់មុខទំនិញ និងសេវាកម្មចាំបាច់មួយចំនួនដែលត្រូវប្រើប្រាស់បន្ទាន់នៅដើមឆ្នាំថវិកា

ក្នុងគោលបំណងធានាឱ្យក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពថវិកា និងអង្គភាពរដ្ឋដទៃទៀតមានមុខទំនិញ និងសេវាកម្មចាំបាច់មួយចំនួនសម្រាប់ប្រើប្រាស់ទាន់ពេលវេលានៅដើមឆ្នាំនៃឆ្នាំថវិកានីមួយៗ ដើម្បីបង្កើនល្បឿននិងប្រសិទ្ធភាពនៃចំណាយថវិកាជាតិ ព្រមទាំងបង្កើនគុណភាពនៃការផ្តល់សេវាសាធារណៈឆាប់រហ័ស និងនៅតែធានាបាននូវតម្លាភាព គណនេយ្យភាព ព្រមទាំងការសន្សំសំចៃក្នុងដំណើរការនៃកិច្ចលទ្ធកម្មសាធារណៈស្របតាមបទប្បញ្ញត្តិនៃច្បាប់ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពថវិកា និងអង្គភាពរដ្ឋដទៃទៀត ចាប់ពីឆ្នាំ២០១៦ តទៅត្រូវអនុវត្តដូចខាងក្រោម÷

១. ត្រូវរៀបចំគម្រោងនិងស្នើសុំធានាចំណាយថវិកាឆ្នាំបន្ទាប់ (ឆ្នាំ N+1) សម្រាប់ការទិញទំនិញ និងសេវាកម្មចាំបាច់និងមានលក្ខណៈជាប្រចាំមួយចំនួនដូចមានជាអាទិ៍÷ សម្ភារការិយាល័យ សៀវភៅសិក្សាគោលនិងកម្មសិទ្ធិបញ្ញា ឯកសណ្ឋាន អាវយឺត (សម្រាប់ទិវាបុណ្យសិទ្ធិនារី៨មីនា) ឱសថ បរិក្ខារពេទ្យ ប្រេងឥន្ធនៈ អង្ករ មី ត្រីខ ចំណីសត្វ និងសេវាសម្អាត មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឬមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត នៅក្នុងត្រីមាសទី៤នៃឆ្នាំ N។

២. ត្រូវស្នើសុំធានាចំណាយដោយឈរលើមូលដ្ឋាន៥០% នៃមុខចំណាយនីមួយៗនៃកញ្ចប់ថវិកាឆ្នាំ N លើកលែងតែក្រសួងមហាផ្ទៃនិងក្រសួងការពារជាតិសម្រាប់ការទិញអង្ករនិងឯកសណ្ឋាន និងក្រសួងអប់រំ យុវជននិងកីឡាសម្រាប់ការបោះពុម្ពសៀវភៅសិក្សាគោលនិងកម្មសិទ្ធិបញ្ញា ដែលអាចអនុញ្ញាតឱ្យស្នើសុំធានាចំណាយច្រើនបំផុតត្រឹម ១០០% នៃថវិកាឆ្នាំN។

៣. ត្រូវរួសរាន់ដំណើរការរៀបចំកិច្ចលទ្ធកម្មសាធារណៈដើម្បីទទួលបានទំនិញ ឬសេវាកម្ម មកប្រើប្រាស់តាមការគ្រោងទុកនៅពេលដែលទទួលបានធានាចំណាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៤. ត្រូវស្នើសុំទូទាត់ជាដំណាក់ៗក្នុងត្រីមាសនីមួយៗនៃឆ្នាំ N+1 ក្រោយពីមានការប្រគល់ទទួលទំនិញ ឬសេវាកម្មជាក់ស្តែង។


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

៥. ត្រូវកត់ត្រាគម្រោងចំណាយលើមុខទំនិញ និងសេវាកម្ម ដែលបានអនុវត្តកិច្ចលទ្ធកម្មក្នុងត្រីមាសទី៤ នៃឆ្នាំ N ដោយប្រើប្រាស់កញ្ចប់ថវិកាឆ្នាំ N+1 ទៅក្នុងតារាងផែនការលទ្ធកម្មប្រចាំឆ្នាំ N+1។

៦. ត្រូវអនុវត្តតាមសារាចរណែនាំលេខ០០២ សហវ.អលសា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ស្ដីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈក្រៅពីមុខទំនិញ និងសេវាកម្មដូចបានកំណត់ក្នុងចំណុចទី១ខាងលើ។

គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពថវិកា និងអង្គភាពរដ្ឋដទៃទៀត ត្រូវទទួលបន្ទុកអនុវត្តសារាចរណែនាំនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០១៥

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ